ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ : ៧៤៥ ........ពណ.ចបព ០១

ថ្ងៃទី.៣១..ខែ.......ឆ្នាំ20០៧

# ប្រកាស

## ស្តីពី

## ការធ្វើវិមជ្ឈការ ការចុះបញ្ជីពាណិជ្ជកម្មនៅមណ្ឌលសាខាខេត្ត-ក្រុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ប្រកាសអោយប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៩១អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។
- បានឃើញសេចក្តីជូនដំណឹងអំពីការអនុវត្តន៍ផែនការ កំណែទំរង់ការចុះបញ្ជីពាណិជ្ជកម្មលេខ ២១០៦ ពណ.នគក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។
- បានឃើញផែនការសំរាប់ការកែទម្រង់ប្រព័ន្ធចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

## សំរេច

**ប្រការ១ :** សំរេចធ្វើវិមជ្ឈការ ការចុះបញ្ជីពាណិជ្ជកម្មនៅតាមមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម នៃបណ្តាខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២ :** មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅក្រោមការដឹកនាំ និង គ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម នឹងត្រូវបានប្រមូលផ្តុំបណ្តាខេត្ត-ក្រុងមួយចំនួន ដែលមានវង្វង់ដែនដីជិតគ្នា អាស្រ័យទៅលើស្ថានភាពសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ និង អាស្រ័យដោយការកំណត់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**ប្រការ៣ :** មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មនៃបណ្តាខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

៣.១ : មជ្ឈមណ្ឌលចុះបញ្ជីពាណិជ្ជកម្ម មានទីតាំងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។ មជ្ឈមណ្ឌលចុះបញ្ជីពាណិជ្ជកម្មរួមមាន : នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ និង ខេត្តកំពង់ឆ្នាំង ។

៣.២ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីមួយ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលក្រុងព្រះសីហនុ និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មក្រុងព្រះសីហនុ ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីពីរ រួមមាន : ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកំពត និងខេត្តកោះកុង ។

៣.៣ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីពីរ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តសៀមរាប និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបីរួមមាន : ខេត្តសៀមរាប និង ខេត្តឧត្តរមានជ័យ ។

៣.៤ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបី ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តកំពង់ចាម និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបីរួមមាន : ខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តព្រះវិហារ ។

៣.៥ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីបួន ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តក្រចេះ និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តក្រចេះ ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំរួមមាន : ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និង ខេត្តរតនគិរី ។

៣.៦ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តស្វាយរៀង និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំមួយ រួមមាន : ខេត្តស្វាយរៀង និង ខេត្តព្រៃវែង ។

៣.៧ : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំមួយ ត្រូវបានកំណត់នាមថា "សាខាចុះបញ្ជីពាណិជ្ជកម្ម" មណ្ឌលខេត្តបាត់ដំបង និងមានទីតាំងនៅមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ។ មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មទីប្រាំពីររួមមាន : ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ និង ក្រុងប៉ៃលិន ។

<u>**ប្រការ៤**</u> : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ដូចមានចែងក្នុងប្រការ ១ ត្រូវបានដឹកនាំ ដោយមន្ត្រីតំណាងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ០១រូប ជាប្រធានសាខា និង មន្ត្រីមួយចំនួននៃមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ជាជំនួយការ ។

<u>**ប្រការ៥**</u>: ធ្វើប្រតិភូកម្មអំណាចពីក្រសួងពាណិជ្ជកម្ម ជូនដល់មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ក្នុងក្របខ័ណ្ឌទទួលពាក្យសុំចុះបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសគ្រប់ប្រភេទទាំងអស់ លើកលែងតែសហគ្រាសវិនិយោគទុនដែលត្រូវចុះបញ្ជី នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

<u>**ប្រការ៦**</u> : មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ប្រើប្រាស់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ទៅតាមទំរង់តែមួយដូចគ្នានឹងទំរង់ដែលប្រើប្រាស់នៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

<u>**ប្រការ៧**</u> : ក្រោយពីបានទទួលសំណុំលិខិត និង ឯកសារសុំចុះបញ្ជីពាណិជ្ជកម្មគ្រប់គ្រាន់តាមច្បាប់គតិយុត្ត ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដែលមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មតាំងនៅ ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីបណ្តោះអាសន្ន ជូនដល់សាមីសហគ្រាស និង ក្រុមហ៊ុន ដែលមានសុពលភាពសំរាប់ប្រើប្រាស់កំណត់ចំនួនត្រឹម ៣០ ថ្ងៃ ។ វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មជាផ្លូវការដែលសំរេចដោយថ្នាក់ដឹកនាំក្រសួង និង ត្រូវបញ្ជូនមកមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុង ដើម្បីប្រគល់ជូនដល់សាមីសហគ្រាសក្រុមហ៊ុនដែលជាអ្នកស្នើសុំ ។

**ប្រការ៨ :** នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ត្រូវចេញសេចក្តីណែនាំអំពីបែបបទ និង នីតិវិធី ស្តីពីការអនុវត្តនីការចុះបញ្ជីពាណិជ្ជកម្ម នៅតាមបណ្តាមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ៩ :** តួនាទី និង ភារកិច្ចរបស់មណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្ម មានដូចតទៅ :

- ពិគ្រោះ និង ផ្តល់យោបល់ ជូនអតិថិជន សហគ្រិន ពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម ។
- ផ្តល់ពត៌មានពីការសំរេចចិត្ត របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អំពីការអនុញ្ញាតអោយប្រើប្រាស់នាមករណ៍ក្រុមហ៊ុនដែលអតិថិជន និង សហគ្រិនបានស្នើឡើងមក ។
- ទទួលពាក្យស្នើសុំ និង សំណុំលិខិតដែលច្បាប់តំរូវ ដើម្បីសុំចុះបញ្ជីពាណិជ្ជកម្ម ហើយបញ្ជូនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម សុំការសំរេចជាផ្លូវការអំពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ។
- ប្រគល់សំណុំឯកសារ និង វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ដែលបានទទួលការសំរេចជាផ្លូវការរួចហើយជូនដល់សាមីសហគ្រាស ក្រុមហ៊ុនអ្នកស្នើសុំ ។
- គ្រប់គ្រង និង ថែរក្សាសំណុំឯកសារទាំងឡាយ របស់ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅតាមមណ្ឌលសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗ ហើយធ្វើរបាយការណ៍ និង ផ្តល់ស្ថិតិប្រចាំខែ ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលមានទីស្នាក់ការតាំងនៅក្នុងមណ្ឌលនិមួយៗផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។
- ដោះស្រាយបញ្ហាដែលកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្ម ឬ បញ្ជូនឯកសារ ទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ក្នុងករណីចាំបាច់ដែលមានបញ្ហាកើតឡើង ។
- ធ្វើការផ្សព្វផ្សាយខ្លឹមសារច្បាប់ និង លិខិតបទដ្ឋាននានា ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម និង ជំរុញការអនុវត្តនីអោយមានប្រសិទ្ធភាព ។

**ប្រការ១០ :** អគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នាយិកាខុទ្ទកាល័យ ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និង ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ប៉ាន សុីផាន

**ចម្លងជូន :**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-ក្រុង
- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ADB TA 4786-CAM
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧

ជ. ប្រធាននាយកដ្ឋានរដ្ឋបាល

**វង្ស មន្តតារា**